**ក្រុមប្រឹក្សាមេធាវីការពារឲ្យជនរងគ្រោះដោយការឆបោក**
**ក្នុងរឿងវិនិយោគទុនលើអចលនទ្រព្យនៅប្រទេសកម្ពុជា**

---

# សេចក្ដីថ្លែងការណ៍

ពាក់ព័ន្ធទៅនឹងសំណុំរឿងឆបោកឲ្យដាក់ទុនវិនិយោគលើអចលន ទ្រព្យនៅប្រទេសកម្ពុជា នៅក្នុងថ្ងៃនេះ សាលាដំបូងប្រចាំតំបន់ Yokohama ផ្នែកបណ្ដឹងព្រហ្មទណ្ឌ បានប្រកាសសាលក្រមផ្ដន្ទាទោស ពីបទឆបោក ដោយសម្រេចឲ្យ (1)ជនជាប់ចោទឈ្មោះ Yonezawa Yasuyuki ជាតំណាងអភិបាលក្រុមហ៊ុនអចលនទ្រព្យ First Fudosan ដែលជាហាងតំណាងលក់នៅប្រទេសជប៉ុន ឲ្យជាប់ពន្ធធនាគាររយៈពេល 10ឆ្នាំ (2)ជនជាប់ចោទឈ្មោះ Imura kazuhiko ជានាយរងនៃក្រុមហ៊ុនខាងលើ ឲ្យជាប់ពន្ធធនាគាររយៈពេល 8ឆ្នាំ6ខែ (3)ជនជាប់ចោទឈ្មោះ Kawanobe Toshio ជាមេក្លោងទី1នៃក្រុមឆបោកតាមទូរសព្ទ័ ឲ្យជាប់ពន្ធធនាគាររយៈពេល 10ឆ្នាំ (4)ជនជាប់ចោទឈ្មោះ Sekiyama Tomo ជាមេក្លោងទី2នៃក្រុមឆបោកតាមទូរសព្ទ័ ឲ្យជាប់ពន្ធធនាគាររយៈពេល 8ឆ្នាំ6ខែ និង(5)ជនជាប់ចោទឈ្មោះ Yoda Naoki ជាសមាជិកនៃក្រុមឆបោកតាមទូរសព្ទ័ ឲ្យជាប់ពន្ធធនាគាររយៈពេល 4ឆ្នាំ6ខែ ។

សហជនជាប់ចោទ បានប្រើប្រាស់មធ្យោបាយរៀបចំបង្កើតចេញជាឈុតឆាកដូចក្នុងល្ខោន ធ្វើឲ្យជនរងគ្រោះលង់ចាញ់បញ្ឆោតក្រោមរូបភាពបញ្ចុះបញ្ចូលឲ្យ ដាក់ទុនវិនិយោគលើអចលន ទ្រព្យនៅប្រទេសកម្ពុជា ដោយយកមនុស្សចាស់ជរាទូទាំងប្រទេសជាគោលដៅ បណ្ដាលធ្វើឲ្យយ៉ាងហោចណាស់មានជនរងគ្រោះរាប់រយនាក់ចាញ់បោកនិងអស់ប្រាក់លើសពី 20លានយ៉េន ហើយជនរងគ្រោះដែលត្រូវបានចាញ់បញ្ឆោតអស់សូម្បីតែប្រាក់សន្សំសំរាប់ចាយពេលចាស់ជរារបស់ខ្លួនក៏មានចំនួនច្រើនផងដែរ ។ អាស្រ័យដូចបានរៀបរាប់ខាងលើ សំណុំរឿងនេះវាគឺជាបទល្មើសដែលប្រព្រឹត្តឡើងដោយមានទ្រង់ទ្រាយធំ មានលក្ខណៈជាប្រព័ន្ធ និងមានគំរោងគិតទុកជាមុន ដែលយើងអាចនិយាយបានថាវាជាបទល្មើសដ៏សែនថោកទាបនិងអាក្រក់បំផុត នៅក្នុងចំណោមបទល្មើសឆបោករឿងវិនិយោគជាច្រើនផ្សេងទៀត ហើយការរងគ្រោះរបស់ ជនរងគ្រោះដែលជា មនុស្សចាស់ជរាក៏មានលក្ខណៈឃោរឃៅផងដែរ ។ គួរបញ្ជាក់ផងដែរថា ប ទល្មើសដែលត្រូវបានប្ដឹងនិង ផ្ដន្ទាទោសនៅក្នុង សំណុំរឿងនេះ គឺគ្រាន់តែជាបទល្មើសមួយផ្នែកតូចនៃបទល្មើសជាច្រើនទៀតដែលសហជនជាប់ចោទបានប្រព្រឹត្តតែប៉ុណ្ណោះ ។

បើយើងពិចារណាពី សតិអារម្មណ៍របស់ជនរងគ្រោះ យើងអាចនិយាយបានថា ការប្រកាសផ្ដន្ទាទោសនៃសាលក្រមក្នុងថ្ងៃនេះវានៅមិនទាន់គ្រប់គ្រាន់នូវឡើយមែនក្ដី ប៉ុន្តែ យើងខ្ញុំសូមអំណរគុណនិងកោតសរសើរដោយស្មោះអស់ពីចិត្ត ចំពោះការខិតខំប្រឹងប្រែងរបស់ព្រះរាជអាជ្ញានិងសមត្ថកិច្ច ដែលបានខិតខំស្រាវជ្រាវ និងជ្រុមជ្រែងរហូតឈានដល់ការបើកសវនការកាត់ទោសជនល្មើស ដោយបានចំនាយរយៈពេលអស់៣ឆ្នាំជាងគិត

ចាប់តាំងពីមានការចាប់ខ្លួនអ្នកពាក់ព័ន្ធលើកដំបូងក្នុងរឿងឆបោកនេះ តាំងពីអំឡុងខែសីហាឆ្នាំ2013 រហូតឈានដល់មានការប្រកាសសាលក្រមក្នុងថ្ងៃនេះ ។

ដោយឡែក បុគ្គលឈ្មោះ កុនណុ អ៊ីគឹអុ (Konno Ikuo) (ឈ្មោះជាភាសាខ្មែរ កុនណុ កក្កដា (Konno Kakada)) ដែលត្រូវជាមេក្លោងពិតប្រាកដក្នុង សំណុំរឿងឆបោកនេះ នៅតែបន្តរស់នៅដោយសេរីនៅលើទឹកដីប្រទេសកម្ពុជាដោយមិនទាន់ត្រូវបានចាប់ខ្លួននូវឡើយ ទោះបីជាតុលាការនៃប្រទេសជប៉ុនបានចេញ ដីកាបង្គាប់ឲ្យចាប់ខ្លួនបុគ្គលរូបនេះពីបទឆបោក ហើយ ប៉ូលីសអន្តរជាតិ ( Interpol)ក៏បានអនុវត្តន៍នីតិវិធីស្នើសុំទៅប្រទេសជាសមាជិកឲ្យជួយផ្តល់ពត៌មានពាក់ព័ន្ធទៅនឹងទីលំនៅនិងពត៌មានផ្សេងៗទៀតរបស់បុគ្គលនេះ( Blue Notice)ក៏ដោយក្តី ។ ជាពិសេស តាមរយៈសវនការនៃរឿងក្តីនេះបានបង្ហាញយ៉ាងច្បាស់លាស់ថា បុគ្គលឈ្មោះ កុនណុ នេះគឺជាអ្នករៀបចំគំរោង និងជាអ្នកបញ្ជា ហើយទឹកប្រាក់ដ៏ច្រើនដែលបានពីការឆបោកនេះត្រូវបានបញ្ជូនទៅឲ្យបុគ្គលឈ្មោះ កុនណុ ដែលកំពុងរស់នៅប្រទេសកម្ពុជា ។ គួរបញ្ជាក់ផងដែរថា បុគ្គលឈ្មោះ កុនណុ នេះបានធ្វើដំណើរទៅកាន់ប្រទេសកម្ពុជានៅឆ្នាំ 2012 ហើយតាំងពីពេលនោះរហូតមកដល់បច្ចុប្បន្ននេះបុគ្គលនេះបានយកប្រទេសកម្ពុជាជាទីតាំងឈរជើង ហើយនៅឆ្នាំ2013ក៏បានប្តូរសញ្ជាតិពីជប៉ុនទៅកម្ពុជា ។ ដូច្នេះហើយ ប្រ សិនបើមិនមានការកាត់ទោសឲ្យបុគ្គលឈ្មោះ កុនណុ នេះទទួលខុសត្រូវខាងព្រហ្មទណ្ឌ នូវទង្វើដែលបានប្រព្រឹត្ត ទេនោះ យើងក៏មិនអាចនិយាយ បានដែរថា រឿងក្តីឆបោកនេះត្រូវបានដោះស្រាយ ចប់ជាស្ថាពរ បានទេ ។ អាស្រ័យហេតុនេះ យើងខ្ញុំសង្ឃឹមយ៉ាងម៉ុតម៉ាំចំពោះព្រះរាជអាជ្ញានិងសមត្ថកិច្ចថា ក្រោមកិច្ចសហប្រតិបត្តិការជាអន្តរជាតិ ព្រះរាជអាជ្ញានិងសមត្ថកិច្ចនឹង បន្តខិតខំប្រឹងប្រែងបន្តសកម្មភាពឲ្យ បានកាន់តែខ្លាំងក្លាជាងមុន ទៀត ដើម្បីចាប់ខ្លួនបុគ្គលឈ្មោះ កុនណុ នេះឲ្យបាន ។

ម៉្យាងវិញទៀត ទោះបីនៅក្នុងប្រទេសជប៉ុនរបស់យើង រឿងឆបោកឲ្យធ្វើវិនិយោគដូចក្នុងរឿងក្តីនេះនៅតែបន្តកើតមានអត់ឈប់ ហើយមធ្យោបាយនៃការឆបោកកាន់តែសាហាវជាងពីមួយឆ្នាំទៅមួយឆ្នាំ និងពេញដោយល្បិចកលមែនក្តី ប៉ុន្តែយើងក៏អាចនិយាយបានថា សាលក្រមព្រហ្មទណ្ឌដែលបានប្រកាសក្នុងថ្ងៃនេះ គឺជាសាល-ក្រមមួយដែលជួយទប់ស្កាត់ការបង្ករបទល្មើសប្រភេទដូចគ្នាកុំឲ្យកើតឡើង ជាបន្តទៀតបាន។

ក្រុមប្រឹក្សាមេធាវីយើងខ្ញុំ ប្តេជ្ញានឹងបន្តកិច្ចសហការជាមួយព្រះរាជអាជ្ញានិងសមត្ថកិច្ច ទាំងនូវដំណាក់កាលស្រាវជ្រាវនិង ដំណាក់កាលបើក សវនការ ហើយព្រមទាំងខិតខំប្រឹងប្រែងបន្តសកម្មភាពជាបន្តទៀត ដើម្បីទាមទារឲ្យបានមកវិញនូវ សំណងនៃការខូចខាត ដែលជនរងគ្រោះបានរងគ្រោះនិងខូចខាត តែ នៅមិនទាន់ទទួលបានសំណង និងដំណោះស្រាយត្រឹមត្រូវ គ្រប់ជ្រុងជ្រោយ នៅឡើយ ៕

**ធ្វើនៅ Tokyo ថ្ងៃទី24 ខែតុលា ឆ្នាំ2016**

**ប្រធានក្រុមប្រឹក្សា**

瀬戸和宏

**លោកមេធាវី SETO KAZUHIRO**